ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:១០៨/២៨.១.២០១៣

សាលដីកា

លេខ:១៥៥ក្រIVអ/២៨.១១.២០១៣

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះ ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើក សវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី២៨.១១.២០១៣ ដែលមានសមាសភាព ដូចតទៅ៖

### សមាសភាពក្រុមប្រឹក្សា

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធាន |
| លោក | [redacted] | ចៅក្រមប្រឹក្សា |
| លោក | [redacted] | ចៅក្រមប្រឹក្សា |

### តំណាងមហាអយ្យការ

លោក [redacted]

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌ លេខ:១០៨ ចុះថ្ងៃទី ២៨.១ ២០១៣ រវាង:

-ជនជាប់ចោទ ឈ្មោះ [redacted] និស្ស័យ ភេទប្រុស ឆ្នាំកំណើត ១៩៩៣ ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើត សង្កាត់ទួលទំពូង រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted] ក្រុងកំពត ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ។

-ត្រូវបានចាប់ខ្លួនថ្ងៃទី០៩.៣.២០១២ បច្ចុប្បន្នជាប់ឃុំខ្លួនបណ្តោះអាសន្ននៅ ពន្ធនាគារ ខេត្តកំពត តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១៨៣ ព្រ.ទ ចុះថ្ងៃទី១១.៣.២០១២ របស់ចៅក្រមស៊ើបសួរ ។

-ជាប់ចោទពីបទៈ ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ប្រព្រឹត្ត
ភូមិអណ្ដូងខ្មែរ សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១០ ខែកុ
ឆ្នាំ២០១២ ។ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា១០ នៃច្បាប់ស្ដីពីក
បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីមាស ភេទស្រី អាយុ១៧ឆ្នាំ ទីកន្លែងកំណើ
ភូមិទ្វីខាងត្បូង ឃុំអណ្ដូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ន ភូមិទ្វីខាងត្ប
[redacted] ។

-ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សឿន ភេទប្រុស អាយុ៤៩ឆ្នាំ មុខរបរកងរា
អាវុធហត្ថ ត្រូវជាឪពុករបស់ជនរងគ្រោះ ។ ទីលំនៅបច្ចុប្បន្ន ភូមិទ្វីខាងត្បូង សង្កាត់អណ្ដូ
ខ្មែរ ក្រុងកំពត ខេត្តកំពត ។

## ឯរឿងហេតុមានដូចតទៅ

-តាមអង្គហេតុដែលបានចោទប្រកាន់ឃើញថាៈ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១
ឈ្មោះ [redacted] និស្ស័យ បានលួងលោម និងបបួល ឈ្មោះ [redacted] ស្រីមាស ភេទស្រ
អាយុ១៧ឆ្នាំ រស់នៅភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត រត់ទៅភ្នំពេញ
ពេលទៅដល់ភ្នំពេញ ឈ្មោះ [redacted]និស្ស័យ បាននាំឈ្មោះ [redacted] ស្រីមាស ទៅស្នាក់នេ
ផ្ទះសំណាក់មួយ នៅទល់មុខមន្ទីរពេទ្យរុស្ស៊ី ចំនួន៣យប់ ។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១
ទើបអ្នកទាំងពីរនាំគ្នាទៅផ្ទះឈ្មោះ [redacted] ពៅ ត្រូវជាម្ដាយរបស់ឈ្មោះ [redacted] និស្ស័យ ដែល
ស្ថិតនៅប៉ោយប៉ែត នោះដែរ ដោយមិនឲ្យឈ្មោះ [redacted] ស្រីមាស ទូរស័ព្ទចេញទៅណា
ឡើយ ។ ក្រោយមកឈ្មោះ [redacted] និស្ស័យ បានទទួលដំណឹងពីពួករបស់ខ្លួនឈ្មោះ [redacted]
ពិសិដ្ឋ ប្រាប់ថាប៉ារបស់ [redacted] ស្រីមាស ឈ្មោះ [redacted]សឿន បានតាមរកដល់ប៉ោយប៉ែ
ហើយឈ្មោះ [redacted] និស្ស័យ ក៏បាននាំឈ្មោះ[redacted] ស្រីមាស ទៅលាក់ខ្លួននៅស្រុកសំឡូ
ស្នាក់នៅផ្ទះឈ្មោះ[redacted]ចន្ថា ត្រូវជាអ៊ុំរបស់ឈ្មោះ [redacted] និស្ស័យ និងបាននាំគ្នាចុះសំបុត្រ
អាពាហ៍ពិពាហ៍នៅសាលាឃុំតាសាញ់ ស្ថិតនៅស្រុកសំឡូត ខេត្តបាត់ដំបង ដោយពុំមានការ
ព្រមព្រៀងពីឪពុកម្ដាយឡើយ ។ ក្រោយមក ឈ្មោះ [redacted] និស្ស័យ និងឈ្មោ[redacted] ស្រីមាស
បាននាំគ្នាត្រឡប់មកភ្នំពេញវិញ ស្នាក់នៅផ្ទះសំណាក់មុខមន្ទីរពេទ្យរុស្ស៊ី រហូតដល់ថ្ងៃទី០៩
ខែមីនា ឆ្នាំ២០១២ ទើបឈ្មោះ[redacted]សឿន ជាឪពុករបស់ឈ្មោះ [redacted] ស្រីមាស បានរកអ្នក
ទាំងពីរឃើញ ហើយនាំមកខេត្តកំពតវិញ ចាប់ឃាត់ខ្លួនឈ្មោះ [redacted] និស្ស័យ ប្រគល់ឲ្យ
សមត្ថកិច្ចកងរាជអាវុធហត្ថស៊ើបអង្កេតកសាងសំណុំរឿងបញ្ជូនមកតុលាការ ។

បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ៩១ "ខ" ចុះថ្ងៃទី០៤.១២.២០១២ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១.ផ្តន្ទាទោសឈ្មោះ [redacted] និស្ស័យ ភេទប្រុស ឆ្នាំកំណើត១៩៩៣ ជាតិខ្មែរ មុខរបរសិស្ស ។ ទីកន្លែងកំណើត សង្កាត់ទួលទំពូង រាជធានីភ្នំពេញ ។ ទីលំនៅបច្ចុប្បន្ន [redacted] ក្រុងកំពត ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ។

ដាក់ពន្ធនាគារកំណត់២ឆ្នាំ "ពីរឆ្នាំ" ។

ពីបទ ការនាំយកអនីតិជនចេញដោយមិនស្របច្បាប់ ។ ប្រព្រឹត្តនៅ ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ ។ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា៨ និងមាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ។

២.អោយឈ្មោះ [redacted] និស្ស័យ ដែលមានសាវតាជាតិដូចខាងលើ បង់សំណងជម្ងឺចិត្តជាប្រាក់ចំនួន៣,០០០,០០០ "បីលាន"រៀល មកអោយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សឿន ។ បណ្តឹងទាមទារសុំលើសពីនេះ បដិសេធចោល ។

៣.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ សេចក្តីសុំប្តឹងតវ៉ាលេខ១៣១ ចុះថ្ងៃទី១៣.១២.២០១២ របស់លោក [redacted] សម្ពស្ស ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៩១ "ខ" ចុះថ្ងៃទី០៤.១២.២០១២ ត្រង់ចំណុចទី១ នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សេចក្តីសុំប្តឹងតវ៉ាលេខ ០១ ចុះថ្ងៃទី២៤.១២.២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សឿន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៩១ "ខ" ចុះថ្ងៃទី០៤.១២.២០១២ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែ៥ ឆ្នាំ២០១៣ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨-៨-២០១៣ ។

**នាពេលសវនាការ:**

-ជនជាប់ចោទ ឈ្មោះ [redacted] និស្ស័យ (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សឿន (វត្តមាន)

-ជនរងគ្រោះ ឈ្មោះ [redacted] ស្រីមាស (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ

-ដើមបណ្តឹង ឈ្មោះ [redacted] សឿន បានឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកនេះព្រោះខ្លួនមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់សាលាដំបូងខេត្តកំពត ដែលសម្រេចផ្តន្ទាទោសជនជាប់ចោទទាបពេក និងសំណងជំងឺចិត្តមានចំនួនតិចតួចព្រោះខ្លួនបានដើររកកូនអស់រយៈពេល២៩ថ្ងៃ ដោយខ្លួនចំណាយប្រាក់អស់ជាច្រើន ខ្លួនជួបការលំបាកណាស់ ទម្រាំរកកូនឃើញ តុលាការសាលាដំបូងកាត់សេចក្តីមកនេះ គឺអត់គុណភាពទេ ដាក់ទោសកម្រិត២ឆ្នាំ និងជម្ងឺចិត្ត៣លានតិចណាស់ គេយកកូនស្រីខ្ញុំទៅដាក់ថ្នាំវង្វេងវង្វាន់ ខ្លួនចាប់បានតាមប្រព័ន្ធទូរស័ព្ទទង្វើនេះ គឺ [redacted] និស្ស័យ ធ្វើដោយមានគម្រោងគិតទុកជា មុន ។

[redacted] និស្ស័យ ផ្ទះវាបើកហាងនៅកំពត ឪពុកម្តាយវានៅប៉ោយប៉ែត មឹងវាមានមុខរបរនាំមនុស្សទៅថៃ ។

-សំណូមពរ: សុំផ្តន្ទាទោសជនជាប់ចោទឲ្យបានធ្ងន់ជាមុន និងសុំទាមទារសំណងជម្ងឺចិត្ត ចំនួន២០,០០០,០០០(ម្ភៃលាន)រៀល ។

-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋាន: ក្រោយពីបានស្តាប់របាយការណ៍ ក្រោយពីបានស្តាប់ការសួរដេញដោល និងក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងមកឃើញថា អង្គហេតុជាការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ គឺជនជាប់ចោទបានប្រើមធ្យោបាយលួងលោម ដើម្បីយកក្មេងចេញពីផ្ទះ បើយើងពិនិត្យឃើញថាស្រលាញ់គ្នា តែឪពុកម្តាយរបស់ជនរងគ្រោះវិញថា ជនជាប់ចោទបានផ្លាស់កន្លែងលាក់ខ្លួនឯសំបុត្រអាពាហ៍ពិពាហ៍មិនស្របច្បាប់ តំណាងមហាអយ្យការយល់ថា ជនជាប់ចោទបានរំលោភលើ មាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មលើផ្លូវភេទគ្រង់ជំពូកទី॥ អំពីលក់-ដូរមនុស្ស មាត្រា៨ បកស្រាយការនាំចេញមិនស្របច្បាប់ ។

សុំពិនិត្យពីគោលបំណងដើម្បីផ្តន្ទាទោសតាមមាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពោះធ្វើអាជីវកម្មផ្លូវភេទ ។ សុំក្រុមប្រឹក្សាពិនិត្យពិចារណាលើអង្គហេតុ

ឡើងវិញ ព្រោះតាមឪពុកជនរងគ្រោះថា ជនជាប់ចោទមានគោលបំណងនាំជនរងគ្រោះយកទៅលក់នៅប្រទេសថៃ ដែលជនជាប់ចោទដឹងពីការរកស៊ីជួញដូរមនុស្ស ។

-ក្រោយពីបានអានចម្លើយជនជាប់ចោទ ។

-ក្រោយពីបានអានចម្លើយជនរងគ្រោះ ។

-ក្រោយពីបានអាន និងស្តាប់ចម្លើយដើមបណ្តឹង ។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍លេខ១៣១ ចុះថ្ងៃ១៣.១២.២០១២ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពត ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបណ្តឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃ២៨.១២.២០១២ របស់ឈ្មោះ [redacted] សឿន ជាដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២.ជនជាប់ចោទ ឈ្មោះ [redacted] និស្ស័យ មិនបានប្តឹងឧទ្ធរណ៍ពីសាលក្រមព្រហ្មទណ្ឌលេខ៩១ "ខ" ចុះថ្ងៃ០៨.ធ្នូ.២០១២ របស់សាលាដំបូងខេត្តកំពត ដែលផ្តន្ទាទោសខ្លួនដាក់ពន្ធនាគារចំនួន២ឆ្នាំ និងឲ្យសងសំណងជម្ងឺចិត្តចំនួន៣លានរៀល ទៅដើមបណ្តឹងនោះទេ សុខចិត្តទទួលយកតាមសេចក្តីសម្រេចនោះហើយ ។

៣.តំណាងអយ្យការអមសាលាដំបូងខេត្តកំពត ប្តឹងឧទ្ធរណ៍គ្រង់ការផ្តន្ទាទោសជនជាប់ចោទ មានកំរិតស្រាលពេកដោយសំអាងថាអំពើនាំអនីតិជនមិនស្របច្បាប់មានកើតឡើងជាញឹកញាប់នៅខេត្តកំពតពិសេសអនីតិជនដែលនាំចេញនេះជានារីភេទ ដែលជាបទល្មើសចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៤.តាមមាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃ១៨.កុម្ភ:.២០០៨ ចែងថា: ជនណានាំយកអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ចេញដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ដល់៥ឆ្នាំ ។

ដោយឈ្មោះ [redacted] ស្រីមាស ជាអនីតិជនមានអាយុ១៧ឆ្នាំហើយ ហើយការដែលនាងចេញពីខេត្តកំពតថ្ងៃ១០.២.២០១២ ម៉ោង៧ព្រឹក ជាមួយជនជាប់ចោទ មកដល់ភ្នំពេញទៅដេកនៅផ្ទះសំណាក់ម៉ុលូទឹកស្អុយ២ទៅ៣យប់ រួចធ្វើដំណើរទៅជាមួយជនជាប់ចោទទៅលាក់ខ្លួននៅប៉ោយប៉ែត ទៅសំឡុតអស់ជាច្រើនថ្ងៃ ហើយត្រឡប់ទៅនៅផ្ទះសំណាក់នៅភ្នំពេញវិញ នៅថ្ងៃ៩.៣.២០១២ ទើបឃាត់ខ្លួន [redacted] និស្ស័យ ឃើញថាកើតឡើងដោយសារជនជាប់ចោទ និងជនរងគ្រោះធ្លាប់មានទំនាក់ទំនងស្រលាញ់គ្នា ហើយក៏មិនឃើញមានការបង្ខិតបង្ខំ និងគំរាមគំហែងពីជនជាប់ចោទដែរ ។

៥.សាលាដំបូងខេត្តកំពតបានធ្វើការអង្កេតលើកយកភស្តុតាងមកសំអាងសព្វគ្រប់អស់ហើយ ។ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយមិនលើកមកសរសេរបញ្ជាក់ជាថ្មីទៀតទេ ។

៦.បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សឿន ធ្វើបានតែលើសំណងរដ្ឋប្បវេណីប៉ុណ្ណោះ តាមមាត្រា៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្នុងការតាមរកកូនស្រី [redacted] ស្រីមាស ឈ្មោះ [redacted] សឿន បានចំណាយពេលវេលាប្រាក់កាសជាច្រើន និងបាត់បង់កិត្តិយសគ្រួសារជាច្រើនដែរ ។ គប្បីក្រុមប្រឹក្សាពិចារណាឡើងវិញ អំពីសំណងរដ្ឋប្បវេណី ដល់ដើមបណ្តឹង ។

៧.សាលក្រមព្រហ្មទណ្ឌលេខ៩១ "ខ" ចុះថ្ងៃ៨.ធ្នូ.២០១២ របស់សាលាដំបូងខេត្តកំពតមានលក្ខណៈត្រឹមត្រូវ លើកលែងតែសំណងជម្ងឺចិត្តត្រង់ចំណុចទី២ នៃសេចក្តីសម្រេចត្រូវកែប្រែតាមការយល់ឃើញខាងលើ ។

## ហេតុដូចនេះ វិនិច្ឆ័យសេចក្តី

១.ទទួលបណ្តឹងឧទ្ធរណ៍ លេខ១៣១ ចុះថ្ងៃ១៣.១២.២០១២ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២.ទទួលបណ្តឹងឧទ្ធរណ៍ លេខ០១ ចុះថ្ងៃ២៨.១២.២០១២ របស់ឈ្មោះ [redacted] សឿន ជាដើមបណ្តឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣.តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ៩១ (ខ) ចុះថ្ងៃ៨.ធ្នូ.២០១២ របស់សាលាដំបូងខេត្តកំពត ទុកជាបានការ លើកលែងតែចំណុចទី២ នៃសេចក្តីសម្រេចត្រង់ឲ្យជនជាប់ចោទ

បង់សំណងជម្ងឺចិត្តទៅអោយដើមបណ្តឹងចំនួន៣លានរៀល ត្រូវកែប្រែទៅជា២០លាន (ម្ភៃលាន)រៀលវិញ ។

៤.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៥.សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted]សៀន បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

សាលដីកានេះមានអានុភាពអនុវត្តតែចំពោះទោសប៉ុណ្ណោះ រីឯប្រាក់សំណងនៅជាប់បណ្តឹងសាទុក្ខ ។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្ត សាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| | | |
|---|---|---|
| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |

ហត្ថលេខា [redacted] ហត្ថលេខា[redacted] , [redacted] ហត្ថលេខា[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី.២១.ខែ.ឧសភា.ឆ្នាំ២០១៤..

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]